សៀវភៅនេះ នឹងប្រើប្រាស់ជាឯកសារសម្រាប់បណ្ដុះបណ្ដាលដល់ក្រុមប្រឹក្សាឃុំ សង្កាត់ស្ដីពី**សកម្មភាពឃុំ សង្កាត់នៅក្នុងកិច្ចការពារកុមារ** និងប្រើប្រាស់ជាឯកសារផ្សព្វផ្សាយចំណេះដឹងទូទៅដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីចូលរួមចំណែកក្នុងកិច្ចការពារកុមារនៅតាមសហគមន៍។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ នឹងទទួលស្វាគមន៍ជានិច្ចចំពោះមតិទិតៀនស្ថាបនាដើម្បីកែលម្អសៀវភៅនេះ។





# ១. កុមារត្រូវការកិច្ចការពារពិសេស



☞ **កុមារ** គឺជាមនុស្សដែលស្ថិតក្នុងដំណើរការវិវឌ្ឍន៍ ហើយមានអាយុពីសូន្យឆ្នាំដល់ក្រោម១៨ឆ្នាំ។

☞ **កុមារដែលងាយរងគ្រោះ** គឺជាកុមារដែលរស់នៅក្នុងកាលៈទេសៈលំបាក ហើយប្រឈមមុខនឹងគ្រោះថ្នាក់ ប៉ុន្ដែពុំទាន់មានការប៉ះពាល់ដល់ការអភិវឌ្ឍរបស់ពួកគេ។

☞ **កុមារដែលត្រូវការកិច្ចការពារពិសេស** គឺជាកុមារដែលស្ថិតក្នុងកាលៈទេសៈលំបាកពិសេស ឬកុមារដែលមានគ្រោះថ្នាក់ ហើយមានការប៉ះពាល់ដល់ការអភិវឌ្ឍរបស់ពួកគេ។

☞ **ការអភិវឌ្ឍរបស់កុមារ** គឺជាដំណើរការ និងយន្ដការដែលត្រូវប្រតិបត្ដិនៅក្នុងរយៈពេលនៃការអភិវឌ្ឍខាងរាងកាយ ចិត្ដសាស្ត្រ និងបញ្ញាស្មារតីរបស់កុមារដើម្បីក្លាយជាមនុស្សពេញវ័យ។

☞ **ដំណាក់កាលនៃការអភិវឌ្ឍកុមារ គឺ :**

- ទារកអាយុពី 0-១២ខែ (១ឆ្នាំ)
- កុមារវ័យដំបូងពី ១-៦ឆ្នាំ
- កុមារវ័យជំទង់អាយុពី ៦-ក្រោម១៨ឆ្នាំ

## ១.១. កុមារដែលត្រូវការកិច្ចការពារពិសេស

កុមារដែលត្រូវការកិច្ចការពារពិសេសមានដូចជា :




- កុមារកំព្រា
- កុមារពិការ
- កុមារត្រូវគេជួញដូរ
- កុមារត្រូវគេបោះបង់ចោល
- កុមារត្រូវគេកេងប្រវ័ញ្ចឱ្យធ្វើការងារប្រកបដោយគ្រោះថ្នាក់
- កុមាររងផលប៉ះពាល់ពីមេរោគអេដស៍ ឬជំងឺអេដស៍
- កុមាររងគ្រោះពីអំពើហិង្សា
- កុមារចាកចេញទៅក្រៅសហគមន៍ដោយគ្មានឪពុកម្តាយទៅជាមួយ
- កុមារទំនាស់នឹងច្បាប់
- កុមារត្រូវគេរំលោភផ្លូវភេទ ឬកេងប្រវ័ញ្ចផ្លូវភេទ





## ១.២. សារៈប្រយោជន៍នៃការចុះសំបុត្រកំណើត

ការចុះសំបុត្រកំណើតកុមារ ជាមូលដ្ឋានគ្រឹះមួយក្នុងកិច្ចការពារកុមារ ដូច្នេះ បើមានទារកកើត ឪពុក ឬម្តាយ មានកាតព្វកិច្ចត្រូវទៅរាយការណ៍ ចុះសៀវភៅអត្រានុកូលដ្ឋានកំណើត នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅសាលាឃុំ ឬសង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុក ម្តាយទារកនោះ **មិនឱ្យហួស៣០ថ្ងៃ**។ ការចុះសំបុត្រកំណើតនេះផ្តល់សារៈប្រយោជន៍ជាច្រើនដូចជា :

### ក). សារៈប្រយោជន៍សម្រាប់កុមារផ្ទាល់

- កុមារមានឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងអត្តសញ្ញាណស្របច្បាប់
- កុមារទទួលបាននូវមធ្យោបាយផ្សេងៗសម្រាប់រស់រាន និងអភិវឌ្ឍន៍
- កុមារមានឯកសារភ្ជាប់សម្រាប់ចុះឈ្មោះចូលរៀនបឋមសិក្សា
- កុមារមានសិទ្ធិទទួលកេរមតិក
- កុមារមានសិទ្ធិការពារខ្លួនពីការធ្វើការងារធ្ងន់ធ្ងរ
- កុមារដែលមានអាយុក្រោម១៣ឆ្នាំ មិនត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌ
- កុមារដែលមានអាយុក្រោម១៥ឆ្នាំទទួលបាននូវការការពារពីច្បាប់ នៅពេលដែលមានមនុស្សពេញវ័យចង់ទំនាក់ទំនងផ្លូវភេទជាមួយខ្លួន។

- កុមារទទួលបាននូវការការពារពីច្បាប់ក្នុងកាតព្វកិច្ចបម្រើជាតិ ដូចជាចូលបម្រើក្នុងជួរកងទ័ពជាដើម ...។ល។

## ខ). សារៈប្រយោជន៍សម្រាប់អាជ្ញាធរមូលដ្ឋាន

- អាចគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋបានត្រឹមត្រូវ
- ងាយស្រួលពិនិត្យតាមដានចំពោះសេវាមូលដ្ឋាន ដែលត្រូវផ្តល់ចំពោះកុមារទៅតាមអាយុ
- ដឹងពីអត្រាកំណើតរបស់កុមារ
- ងាយស្រួលទប់ស្កាត់ការកេងប្រវ័ញ្ចពលកម្មកុមារ
- អាចជួយឱ្យការចាក់ថ្នាំបង្ការបានដល់កុមារសុក្រឹត
- កុមារអាចចូល រៀនតាមអាយុពិតប្រាកដ។





# ២. កុមារដែលត្រូវគេបោះបង់ចោល និងកុមារកំព្រា

☞ **កុមារដែលត្រូវគេបោះបង់ចោល** គឺជាកុមារដែលឪពុកម្តាយ ឬអ្នកផ្តល់ការថែទាំ បឋមទុកចោលនៅតាមមន្ទីរពេទ្យ តាមទីសាធារណៈ ឬនៅកន្លែងណាមួយ ហើយចាកចេញទៅកាន់កន្លែងមួយផ្សេងទៀត ឬជាកុមារដែលឪពុកម្តាយបដិសេធពុំមើលថែ។



☞ **កុមារកំព្រា** គឺកុមារដែលគ្មានឪពុកម្តាយ (ឪពុក ម្តាយស្លាប់)។

**តើត្រូវដោះស្រាយយ៉ាងដូចម្តេច ចំពោះកុមារត្រូវគេបោះបង់ចោល និងកុមារកំព្រា?**

**ដំណោះស្រាយអាចមានដូចជា :**

- ស្វែងរកមធ្យោបាយសម្រាប់ថែទាំកុមារក្នុងរយៈពេលខ្លី។ តើកុមារមានញាតិសន្តាននៅក្នុងភូមិ ឬនៅភូមិក្បែរដែរឬទេ?
  - បើមានញាតិសន្តាន ពួកគេប្រហែលជាអាចទទួលកុមារទាំងនេះទៅចិញ្ចឹមមួយរយៈ។

   – បើគ្មានញាតិសន្តានទេ ប្រហែលជាអ្នកជិតខាងដែលមានសន្តានចិត្តល្អ អាចទទួលយកកុមារទាំងនេះទៅថែរក្សាមួយរយៈបាន ។
   – បើគ្មានញាតិសន្តាន និងអ្នកជិតខាងណាអាចថែទាំកុមារទាំងនេះក្នុងរយៈពេលខ្លីបានទេ ត្រូវបញ្ជូនកុមារទាំងនេះទៅកន្លែងស្នាក់នៅសុវត្ថិភាពបណ្តោះអាសន្ន ដូចជាវត្តអារាម មណ្ឌលកុមារកំព្រា . . . ។ល ។

- ប្រឹងប្រែង ព្យាយាមទាក់ទង ឬស្វែងរកឪពុកម្តាយរបស់កុមារ ។ ប្រហែលជាញាតិសន្តានដទៃទៀត ដឹងថាឪពុកម្តាយរបស់កុមារនេះនៅឯណា ឬមេភូមិ មេឃុំ ចៅសង្កាត់អាចតាម រកឪពុកម្តាយ ។ ការស្វែងរកទាំងនេះត្រូវចំណាយកម្លាំង ធនធាន និងពេលវេលាច្រើន ប៉ុន្តែវាជាការសំខាន់សម្រាប់អនាគតរបស់កុមារ ។
- ប្រសិនបើអាចទាក់ទងជាមួយឪពុកម្តាយបាន ឪពុកម្តាយត្រូវសម្រេចចិត្ត ថាតើត្រូវត្រឡប់មកមើលថែកូនៗរបស់ខ្លួនវិញ ឬបោះបង់កូនចោល ។ បើឪពុកម្តាយសម្រេចចិត្តបោះបង់កូនចោល អ្នកត្រូវទាក់ទងមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ ដើម្បីស្វែងរកការថែទាំរយៈពេលយូរអង្វែងសម្រាប់កុមារទាំងនោះ ។



២. កុមារដែលត្រូវគេបោះបង់ចោល និងកុមារកំព្រា

- ប្រសិនបើមានអ្នកជិតខាងនៅក្នុងភូមិមានបំណង និងមានលទ្ធភាពទទួលយកកុមារទៅចិញ្ចឹម នោះគឺជាដំណោះស្រាយមួយដ៏ប្រសើរបំផុត ដោយសារតែកុមារនោះអាចបន្តរស់នៅក្នុងភូមិកំណើត ហើយអាចទៅរៀនជាមួយមិត្តភក្តិរបស់ពួកគេបន្តទៀតបាន ។
- ឬអាចប្រើមធ្យោបាយសមស្របផ្សេងទៀត ដែលអាចជួយដល់កុមារបាន ។

# ៣. កុមាររស់នៅក្នុងគ្រួសារដែលមានអំពើហិង្សា



អំពើហិង្សាក្នុងគ្រួសារ សំដៅលើអំពើហិង្សា ឬការរំលោភបំពានផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត និងផ្នែកជីវភាពសេដ្ឋកិច្ច ដែលត្រូវបានប្រព្រឹត្តដោយមនុស្សម្នាក់ ឬច្រើននាក់ ដើម្បីត្រួតត្រាលើមនុស្សផ្សេងទៀតដែលកំពុងរស់នៅក្នុងគ្រួសារនោះ ។

## ៣.១. ផលប៉ះពាល់នៃអំពើហិង្សាក្នុងគ្រួសារលើកុមារ

កុមារដែលរស់នៅក្នុងគ្រួសារ ដែលមានអំពើហិង្សាក្នុងគ្រួសារអាចទទួលរងផលប៉ះពាល់ភ្លាមៗ និងផលប៉ះពាល់រយៈពេលយូរ ។

**ក). ផលប៉ះពាល់ភ្លាមៗ មានដូចជា :**

- របួសលើរូបរាងកាយដូចជា ស្នាមជាំ បាក់ដៃ បាក់ជើង បាក់ឆ្អឹង ជាំភ្នែក . . .
- ដេកមិនលក់ យល់សប្តិអាក្រក់
- ហូបមិនបាន
- មានភាពតានតឹងក្នុងអារម្មណ៍
- មិនចង់លេងសើចជាមួយកុមារដទៃ ឬផ្តាច់ខ្លួនពីសង្គម





- ពិបាកទំនាក់ទំនងជាមួយអ្នកដទៃ ដូចជា មិនចូលចិត្តឱ្យគេប៉ះ
- កើតទុក្ខ ក្រៀមក្រំ និងមានភាពស្រងេះស្រងោច
- មានសភាពភ័យខ្លាច
- ឆាប់ខឹង ងាយនឹងប្រព្រឹត្តអំពើឃោរឃៅ
- មានបញ្ហាក្នុងការផ្តោតអារម្មណ៍ ឬរៀនមិនពូកែ
- ខ្វះការជឿជាក់លើខ្លួនឯង

**ខ). ផលប៉ះពាល់រយៈពេលយូរ មានដូចជា :**

- កុមារដែលទទួលរងអំពើហិង្សាក្នុងគ្រួសារញឹកញាប់ ពិបាកដឹងពីវិធីដោះស្រាយទំនាស់ឱ្យបានត្រឹមត្រូវ
- កុមារអាចចម្លងយកឥរិយាបថពីឪពុកម្តាយ ដូចជាពេលធំពេញវ័យ គេអាចក្លាយទៅជាអ្នកប្រព្រឹត្តអំពើហិង្សាទៅលើមិត្តភក្តិ ឬប្រពន្ធ ប្តី ឬគេអាចក្លាយជាអ្នកដែលព្រមទទួលយក និងស៊ូទ្រាំអត់ធ្មត់រស់ក្នុងអំពើហិង្សាជាដើម ។
- កុមាររងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ អាចរត់ចេញពីផ្ទះ និងអាចក្លាយជាកុមាររស់នៅតាមចិញ្ចើមថ្នល់ ។

## ៣.២. ដំណោះស្រាយ

ដំណោះស្រាយចំពោះកុមារ ដែលទទួលរងគ្រោះថ្នាក់ដោយសារអំពើហិង្សាក្នុងគ្រួសារអាចមានដូចជា ៖

### ក). ចំពោះករណីស្រាល

- បើញាតិសន្តាន គ្រូបង្រៀន អ្នកជិតខាង ព្រះសង្ឃ មិត្តភក្តិសង្ស័យថាកុមារត្រូវគេវាយដំ ត្រូវរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុតដូចជា មេភូមិ មេឃុំ ឬទៅអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតដើម្បីសុំអន្តរាគមន៍។
- បើមានអំពើហិង្សាក្នុងគ្រួសារកើតឡើងម្តងម្កាល ឬពុំសូវញឹកញាប់ សាច់ញាតិ ចាស់ទុំ មិត្តភក្តិ មេភូមិ មេឃុំ ចៅសង្កាត់ ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀតធ្វើការអប់រំណែនាំដល់ឪពុកម្តាយ ឬអ្នកប្រព្រឹត្តិហិង្សាថា ការវាយដំកូនមិនត្រឹមតែបង្កគ្រោះថ្នាក់ដល់រាងកាយ ផ្លូវចិត្ត និងសុខភាពខាងសតិអារម្មណ៍របស់កុមារប៉ុណ្ណោះទេ ប៉ុន្តែការវាយដំកុមារ ក៏អាចបណ្តាលឱ្យមានរបួសធ្ងន់ធ្ងរ ហើយជាសកម្មភាពដែលប្រឆាំងនឹងច្បាប់របស់ប្រទេសកម្ពុជាយើងទៀតផង។ ដូច្នេះ បើអ្នកវាយដំកូនធ្ងន់ធ្ងរនោះ អ្នកត្រូវមានទោស ហើយអាចជាប់ពន្ធនាគារទៀតផង។ ហេតុផលនេះអាចគ្រប់គ្រាន់ឱ្យឪពុក ម្តាយបញ្ឈប់ការវាយដំកូនរបស់គេ។





### ខ). ចំពោះករណីធ្ងន់ធ្ងរ

- បើការរំលោភបំពានមានភាពធ្ងន់ធ្ងរខ្លាំង ឬកើតមានជាបន្តបន្ទាប់ ឬមានរយៈពេលយូរ ឬកើតឡើងជាប្រចាំ មេភូមិ ឬភ្នាក់ងារស្ម័គ្រចិត្តភូមិ (ក្នុងតំបន់មានបណ្តាញការពារកុមារ) ត្រូវរាយការណ៍ទៅមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ឬអ្នកមានសមត្ថកិច្ចដទៃទៀតដើម្បីសុំការធ្វើអន្តរាគមន៍។
- បើមានលទ្ធភាពត្រូវនាំកុមារចេញពីផ្ទះបណ្តោះអាសន្ន ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ (ករណីនេះឪពុកម្តាយ ឬអាណាព្យាបាលអាចនឹងត្រូវបាត់បង់អំណាចមេបាទៅលើកុមារ)។
- ចំណុចដែលសំខាន់បំផុតនោះគឺសុវត្ថិភាព និងសុខុមាលភាពរបស់កុមារ។ បើកុមារអាចស្នាក់នៅបណ្តោះអាសន្នជាមួយញាតិសន្តាន ឬអ្នកជិតខាងនៅក្នុងសហគមន៍ នេះគឺជាដំណោះស្រាយយ៉ាងល្អបំផុត។
- តែបើសិនជាកុមារស្នាក់នៅបណ្តោះអាសន្នជាមួយសាច់ញាតិ ឬអ្នកជិតខាងក្នុងសហគមន៍ ហើយនៅតែទទួលរងការវាយដំដោយឪពុក ម្តាយ ឬអាណាព្យាបាលទៀត ត្រូវបញ្ជូនកុមារទៅមណ្ឌលសង្គ្រោះ ឬអង្គការមិនមែនរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្សនៅក្រៅសហគមន៍។

- ស្វែងរកមណ្ឌលដែលអាចផ្តល់ជម្រកឱ្យស្ត្រីដែលរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ និងកូនរបស់គេអាចទៅស្នាក់នៅបណ្តោះអាសន្នបាន។
- ក្នុងរាល់ករណីខាងលើ កុមារ និងជនរងគ្រោះផ្សេងទៀត (អាចជាម្តាយ...) ដែលបានទទួលរងការវាយដំ ត្រូវការចាំបាច់នូវការគាំទ្រខាងផ្លូវចិត្ត ព្រោះគេអាចមានអារម្មណ៍ថា ការវាយដំទាំងនេះ មិនមែនជាកំហុសរបស់ជនមុខសញ្ញាឡើយ តែវាគឺជាកំហុសរបស់ខ្លួនពួកគេផ្ទាល់ ដូចជា កុមារអាចយល់ថា គេគឺជាក្មេងមិនល្អ ឯស្ត្រីអាចមានអារម្មណ៍ថា គាត់ជាប្រពន្ធមិនល្អជាដើម។ ដូច្នេះអ្នកជិតខាង មេភូមិ មេឃុំ ចៅសង្កាត់ និងអ្នកពាក់ព័ន្ធដទៃទៀត ត្រូវផ្តល់នូវការលើកទឹកចិត្ត និងគាំទ្រដល់កុមារ និងស្ត្រីទាំងនោះជាចាំបាច់ បើមិនដូច្នោះទេ ពួកគេនឹងទទួលរងនូវការវាយដំកាន់តែខ្លាំងថែមទៀត។





# ៤. កុមារដែលត្រូវគេរំលោភផ្លូវភេទ

ការរំលោភផ្លូវភេទលើកុមារ គឺជាសកម្មភាពនៃការរំលោភសេពសន្ថវៈ ការបៀតបៀនកេរ្តិ៍ខ្មាស ការប្រព្រឹត្តអំពើអាស្រូវភាស និងសកម្មភាពរំលោភផ្លូវភេទផ្សេងទៀតដើម្បីបន្ទាបបន្ថោកដល់កុមារ ទោះជាកុមារនោះព្រម ឬមិនព្រមក្តី។

## ៤.១. ផលប៉ះពាល់នៃការរំលោភផ្លូវភេទលើកុមារ

បន្ទាប់ពីទទួលរងនូវការរំលោភផ្លូវភេទ កុមារនឹង :

- ទទួលផលប៉ះពាល់ជាអវិជ្ជមានលើការអភិវឌ្ឍផ្នែកស្មារតី និងផ្នែកសង្គម
- ទទួលការឈឺចាប់ផ្នែករាងកាយ និងផ្លូវចិត្ត
- សុខភាពទ្រុឌទ្រោម បាត់បង់សមត្ថភាពពលកម្ម និងសមត្ថភាពបញ្ញា
- ឆ្លងជំងឺកាមរោគផ្សេងៗ ពិសេសជំងឺអេដស៍
- ក្លាយជាមនុស្សឆេវឆាវ ចូលចិត្តប្រើអំពើហិង្សា ហើយពិបាកសម្របខ្លួនជាមួយអ្នកដទៃ
- មានការភ័យខ្លាចនៅពេលនៅតែម្នាក់ឯង
- គ្មានជំនឿលើខ្លួនឯង
- ទទួលការរើសអើងក្នុងសង្គម
- អស់សង្ឃឹមក្នុងជីវិត

- មានផ្ទៃពោះ
- អាចក្លាយជាឪពុក ម្តាយដែលមានចរិតឃោរឃៅ
- រត់ចេញពីផ្ទះ
- ធ្វើអត្តឃាត
- លែងជឿទុកចិត្តលើមនុស្សពេញវ័យ
- . . . ។ល។

## ៤.២. ល្បិចកលជនល្មើស

ដើម្បីអូសទាញ និងបោកបញ្ឆោតជនរងគ្រោះ ពិសេសកុមារ ជនល្មើសបានប្រើមធ្យោបាយមួយចំនួនដូចជា ៈ

- សន្យាផ្តល់ការងារធ្វើ ដោយឱ្យប្រាក់ខែខ្ពស់
- លួងលោម ទិញទឹកចិត្តកុមារ ឬគ្រួសារកុមារដោយឱ្យប្រាក់កាស គ្រឿងអលង្ការ ឬសង់ផ្ទះឱ្យជាដើម
- ប្រើល្បិចស្តីដណ្តឹងរៀបការ រួចយកទៅលក់នៅបរទេស
- សុំធ្វើជាកូនធម៌ ឬបងប្អូនធម៌
- អូសទាញឱ្យចូលរួមពិធីជប់លៀង ហូបចុកក្នុងរង្គសាល ឬផ្ទះសំណាក់
- បញ្ឆោតឱ្យដើរលេងជាមួយនៅកន្លែងស្ងាត់ កន្លែងងងឹត ឬកន្លែងបិទជិត ហើយចាប់រំលោភ។
- ប្រើថ្នាំសណ្តំ





- សុំធ្វើជាសង្សារ ឬគូកំណាន់ចិត្ត
- . . . ។ល។

រាល់ការប្រើប្រាស់ល្បិចកលទាក់ទាញទឹកចិត្តមនុស្សម្នាក់ ឬច្រើននាក់ ក្នុងគោលបំណងដើម្បីជួញដូរ លក់ ឬឱ្យធ្វើពេស្យាចារ ដោយមិនគិតថាអ្នកនោះយល់ព្រម ឬមិនយល់ព្រមនោះទេ ត្រូវផ្តន្ទាទោស ហើយត្រូវដាក់ទម្ងន់ទោសបន្ថែម បើជនរងគ្រោះជាកុមារអាយុក្រោម១៥ឆ្នាំ (មាត្រា៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស)។

## ៤.៣. ការអន្តរាគមន៍ករណីការរំលោភផ្លូវភេទលើកុមារ

ក្នុងករណីមានការរំលោភផ្លូវភេទលើកុមារកើតមានឡើង ឪពុកម្តាយ សាច់ញាតិ ឬអ្នកដទៃទៀតគួរតែផ្តល់ព័ត៌មានទៅមេភូមិ មេឃុំ ចៅសង្កាត់ អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ នគរបាល មន្ត្រីសង្គមកិច្ចស្រុកខណ្ឌ និងអ្នកមានសមត្ថកិច្ចផ្សេងទៀតឱ្យបានឆាប់រហ័ស ដើម្បីសុំអន្តរាគមន៍។

មេឃុំ ចៅសង្កាត់ មេភូមិ ឪពុកម្តាយ សាច់ញាតិ និងអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ត្រូវចាត់វិធានការនានាដើម្បីធានាសុវត្ថិភាពដល់កុមារ ដូចជា ៈ

- ចេញឯកសារស្របច្បាប់បណ្តោះអាសន្ន ស្តីពីការចាត់ចែងទៅលើការថែទាំកុមារ

- បញ្ជូនកុមារទៅមជ្ឈមណ្ឌលផ្ដល់ទីជម្រក និងការថែទាំ (បើចាំបាច់)
- នាំកុមារទៅទទួលការផ្ដល់ប្រឹក្សាយោបល់ និងការថែទាំពីអ្នកដែលមានជំនាញ ជាពិសេសពីមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ ឬពីអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដូចជាអង្គការលីកាដូ អាដហុក ធីភីអូ ឬមណ្ឌលនានាដែលផ្ដល់សេវាទាំងនេះ។
- បញ្ជូនកុមារទៅពិនិត្យសុខភាពនៅមណ្ឌលសុខភាព ក្នុងរយៈពេល២៤ម៉ោង បន្ទាប់ពីពេលកើតហេតុ ដើម្បីរកភស្តុតាងនៃបទល្មើសព្រហ្មទណ្ឌ។
- ត្រូវរៀបចំដាក់ពាក្យបណ្ដឹងព្រហ្មទណ្ឌ ជាជាងទទួលយកការសងជំងឺចិត្តពីជនល្មើសជាទឹកប្រាក់ ឬជាការរៀបចំចាត់ចែងការរៀបការ
- អប់រំប្រជាពលរដ្ឋក្នុងសហគមន៍ឱ្យយល់ច្បាស់ថា កុមារជាជនរងគ្រោះដោយសារការរំលោភបំពាន ដូច្នេះយើងត្រូវជួយដល់កុមាររងគ្រោះទាំងនោះ ហើយមិនត្រូវរើសអើង ឬស្អប់ខ្ពើមពួកគេទេ។ លើសពីនេះទៀត យើងត្រូវតែប្រឆាំងនូវរាល់ទង្វើនៃការរំលោភបំពានទាំងនេះ។





# ៥. កុមារត្រូវគេកេងប្រវ័ញ្ចកម្លាំងពលកម្ម

## ៥.១. ពលកម្មកុមារ



ពលកម្មកុមារ គឺជាការងារដែលតម្រូវឱ្យកុមារធ្វើការច្រើនម៉ោងក្នុងមួយថ្ងៃៗ សម្រាប់ប្រាក់កម្រៃដ៏តិចតួច ហើយជាទូទៅស្ថិតក្នុងស្ថានភាពប្រកបដោយគ្រោះថ្នាក់ដល់ការរីកលូតលាស់នៃរាងកាយ និងខួរក្បាលរបស់ពួកគេ ឬបំបែកពួកគេចេញពីគ្រួសារ និងជាញឹកញាប់កាត់ផ្ដាច់ពួកគេចេញពីការសិក្សា។ នៅពេលដែលកុមារត្រូវបានគេកេងប្រវ័ញ្ចកម្លាំងពលកម្ម និងបង្ខំឱ្យធ្វើការប្រកបដោយគ្រោះថ្នាក់ នោះពួកគេនឹងរងគ្រោះថ្នាក់ដល់ការអភិវឌ្ឍផ្នែករាងកាយ ការសិក្សា ស្មារតី ចិត្ត គំនិត និងផ្នែកសង្គម។

ការងារដែលប្រកបដោយគ្រោះថ្នាក់ ត្រូវបានហាមឃាត់ដោយច្បាប់ចំពោះកុមារអាយុក្រោម១៨ឆ្នាំ។ យោងមាត្រា១៧៥ និង១៧៧ នៃច្បាប់ស្ដីពីការងារ(របស់កម្ពុជាឆ្នាំ១៩៩៧)ចែងថា : អាយុអប្បបរមាអាចចូលធ្វើការងារត្រូវបានកំណត់ត្រឹម១៥ឆ្នាំ។ អាយុអប្បបរមារអាចចូលធ្វើការងារ ត្រូវកំណត់ត្រឹម១៨ឆ្នាំ ចំពោះមុខរបរ ឬការងារគ្រប់ប្រភេទដែលអាចធ្វើឱ្យខូចសុខភាព សន្តិសុខ ឬសីលធម៌របស់មនុស្សវ័យជំទង់

ដោយសារតែល័ក្ខខ័ណ្ឌ ឬប្រភេទមុខរបរ និងការងារទាំងនោះបង្កឡើង។ ការងារពេលយប់នៅក្នុងសហគ្រាស ត្រូវបានហាមឃាត់ចំពោះកុមារដែលមានអាយុតិចជាង១៨ឆ្នាំ ប៉ុន្តែអាចអនុញ្ញាតបានចំពោះករណីលើកលែង (ប្រកាសរបស់ក្រសួងទទួលបន្ទុកវិស័យការងារ) ចំពោះកុមារដែលមានអាយុច្រើនជាង១៦ឆ្នាំ។

ទោះបីជាអាយុស្របច្បាប់របស់កុមារ អាចធ្វើការក្នុងស្ថានភាពមិនធ្ងន់ធ្ងរពី១៥-១៨ឆ្នាំក៏ដោយ ក៏ច្បាប់ការងារកម្ពុជាបានចែងថា កុមារទាំងនោះត្រូវទទួលការហ្វឹកហ្វឺនមុននឹងអនុញ្ញាតឱ្យចូលធ្វើការ។ អង្គការពលកម្មអន្តរជាតិបានប៉ាន់ប្រមាណថា មានកុមារកម្ពុជាអាយុក្រោម១៨ឆ្នាំចំនួន២៥២.៩៥៥នាក់ ត្រូវគេជួលឱ្យធ្វើការងារក្រោមទម្រង់នៃពលកម្មកុមារដ៏ធ្ងន់ធ្ងរ (របាយការណ៍របស់ក្រសួងផែនការ និងអង្គការពលកម្មអន្តរជាតិឆ្នាំ២០០១)។

## ៥.២. ប្រភេទការងារប្រកបដោយគ្រោះថ្នាក់

ការងារប្រកបដោយគ្រោះថ្នាក់ចំពោះកុមារមានដូចជា :

- កុមារធ្វើការនៅសណ្ឋាគារ និងភោជនីយដ្ឋាន ជាអ្នកចំអិនអាហារ អ្នកបម្រើតាមបន្ទប់ អ្នកលក់ស្រាបៀរ
- កុមារធ្វើការនៅពេលយប់ (លើកលែងស្ថានភាពមួយចំនួន និងប្រសិនបើកុមារមានអាយុលើសពី១៦ឆ្នាំ)





- កុមារធ្វើការជាអ្នកបម្រើតាមផ្ទះ ឬជាអ្នកយាមទ្វារ
- កុមារវ័យក្មេងធ្វើការក្នុងសិប្បកម្មឡឥដ្ឋ រោងចក្រកាត់ដេរ សិប្បកម្មលោហៈធាតុ ឬនៅជុំវិញគ្រឿងចក្រដែលអាចមានគ្រោះថ្នាក់ រោងចក្រកែច្នៃត្រី ចម្ការកៅស៊ូ ស្រែអំបិល
- កុមារដែលធ្វើការនៅទីកន្លែង ដែលគេអាចទទួលរងគ្រោះដោយការកេងប្រវ័ញ្ចលើរាងកាយ ពាក្យសំដី ឬផ្លូវភេទ ឬទីកន្លែងដែលគេត្រូវដាក់បង្ហាញដើម្បីការសរសេររឿង រូបភាពអាសអាភាស ឱ្យធ្វើសកម្មភាពប្រឆាំងនឹងច្បាប់ ឬការប្រព្រឹត្តអនាចារ។
- ដឹកជញ្ជូនទំនិញឆ្លងកាត់ព្រំដែន (ដឹកធ្ងន់ៗ)
- កន្លែងគំនរសំរាម
- ...។ល។

## ៥.៣. ផលប៉ះពាល់ពីការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ

ការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ ផ្តល់ផលប៉ះពាល់ជាអវិជ្ជមានជាច្រើនដូចជា :

- កុមារលូតលាស់មិនបានល្អ (ក្រិន)
- កុមារមានស្នាកោង
- កុមារខ្សោយកម្លាំង និងពិការដៃ ជើង និងអវៈយវៈ

- កុមារកាន់តែទទួលរងគ្រោះដោយត្រូវគេជួញដូរ រំលោភបំពាន ឬកេងប្រវ័ញ្ច
- កុមារទទួលរងនូវភាពឯកោ ដោយសារគេត្រូវចាកចេញពីសហគមន៍ ដើម្បីមកធ្វើការដែលនាំឱ្យមានការប៉ះពាល់ដល់ការអភិវឌ្ឍរាងកាយ ផ្លូវចិត្ត និងប្រាជ្ញាស្មារតី
- កុមារមិនបានទទួលការសិក្សា អប់រំ និងមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីមើលថែឪពុកម្តាយរបស់គេ
- អាចធ្វើឱ្យកុមារស្លាប់
- សង្គមជាតិបាត់បង់ធនធានមនុស្សទៅថ្ងៃអនាគត
- ពលកម្មកុមារ ជាមូលហេតុនាំឱ្យមានភាពក្រីក្រ ។

## ៥.៤. ការអន្តរាគមន៍

### ក). ករណីកុមារធ្វើការងារតាមការបញ្ជារបស់ឪពុកម្តាយ

- ក្រុមប្រឹក្សាឃុំ សង្កាត់ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ មេភូមិ ត្រូវធ្វើការផ្សព្វផ្សាយ និងពន្យល់ដល់ឪពុក ម្តាយអំពីផលប៉ះពាល់ជាអវិជ្ជមាននៃការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ
- ក្រុមប្រឹក្សាឃុំ សង្កាត់ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ មេភូមិ ត្រូវរាយការណ៍ទៅមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ ឬបញ្ជូនករណីទាំងនោះទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ក្រុង ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ ។ ឪពុក ម្តាយអាចបាត់បង់សិទ្ធិទៅលើកូន ហើយត្រូវផ្តន្ទាទោសតាមច្បាប់ ។





- មេឃុំ ចៅសង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ មន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធផ្សេងទៀតអាចទៅសួរសុខទុក្ខកុមារ ផ្តល់កម្លាំងចិត្ត និងផ្តល់នូវការថែទាំសមស្រប ។

### ខ). ករណីកុមាររត់ចេញពីផ្ទះដោយត្រូវគេលួងលោមបោកប្រាស់

- ក្រុមប្រឹក្សាឃុំ សង្កាត់ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ មេភូមិ ត្រូវធ្វើការផ្សព្វផ្សាយ និងពន្យល់ដល់ប្រជាពលរដ្ឋក្នុងភូមិអំពីផលប៉ះពាល់ជាអវិជ្ជមាននៃការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ
- ឪពុកម្តាយ សាច់ញាតិ អ្នកជិតខាង និងអ្នកផ្សេងទៀតដែលបានដឹងត្រូវផ្តល់ព័ត៌មានទៅមេឃុំ ចៅសង្កាត់ មេភូមិ នគរបាលប៉ុស្តិ៍ឃុំ សង្កាត់ មន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ និងអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតដើម្បីសុំអន្តរាគមន៍
- មេឃុំ ចៅសង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ មន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធផ្សេងទៀតអាចទៅសួរសុខទុក្ខកុមារ ផ្តល់កម្លាំងចិត្ត និងផ្តល់នូវការថែទាំសមស្រប ។

- បើឳពុកម្តាយក្រីក្រខ្លាំងពេក ពុំអាចទទួលកូនឱ្យត្រឡប់មករស់នៅក្នុងគ្រួសារវិញ ក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ មន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ និងអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតត្រូវទំនាក់ទំនងជាមួយស្ថាប័ន ដែលអាចផ្តល់ជំនួយបាន ដូចជាអង្គការមិនមែនរដ្ឋាភិបាល ឬសប្បុរសជននានា ដើម្បីការពារកុមារពីពលកម្មប្រកបដោយគ្រោះថ្នាក់ និងអាចឱ្យគេទៅសាលារៀនបាន ។





# ៦. កុមារចាកចេញពីសហគមន៍ ដោយគ្មានឳពុកម្តាយទៅជាមួយ

កុមារដែលចាកចេញពីសហគមន៍ដោយគ្មានឳពុកម្តាយទៅជាមួយ គឺជាការនាំកុមារចេញពីលំនៅដ្ឋានដែលគេធ្លាប់រស់នៅជាប្រក្រតី ទៅកាន់កន្លែងដទៃទៀតនៅក្នុងប្រទេស ឬក្រៅប្រទេស ដើម្បីគោលបំណងណាមួយដោយមិនមានឳពុកម្តាយទៅជាមួយ ។

## ៦.១. មូលហេតុដែលនាំឱ្យកុមារចាកចេញពីសហគមន៍

មូលហេតុដែលនាំឱ្យកុមារចាកចេញពីសហគមន៍មានដូចជា :

- ស្វែងរកការងារនៅតាមទីរួមខេត្ត ក្រុង តាមទីប្រជុំជនក្នុង និងក្រៅប្រទេស
- ជីវភាពក្រីក្រ
- អូសទាញពីអ្នកបោកបញ្ឆោត (មេខ្យល់)
- ចាកចេញទៅដោយខ្លួនឯង
- ទទួលរងការធ្វើបាបដោយសារអំពើហិង្សាក្នុងគ្រួសារ
- ទទួលព័ត៌មានពីការជ្រើសរើសបុគ្គលិក ឬកម្មករ
- . . . ។ល។

## ៦.២. ភាពគ្រោះថ្នាក់

កុមារដែលចាកចេញពីសហគមន៍ដោយមិនមានឪពុកម្ដាយទៅជាមួយ អាចជួបប្រទះបញ្ហាមួយចំនួនដូចជា :

- កុមារត្រូវបែកពីគ្រួសារ ពីបណ្ដាញសហគមន៍ និងពីយន្ដការការពារជាទូទៅ ។
- កុមារងាយចាញ់បោកគេ ឬប្រព្រឹត្តសកម្មភាពដែលផ្ទុយនឹងច្បាប់
- ក្នុងករណីការចាកចេញទៅក្រៅប្រទេស ជាញឹកញាប់កុមារពុំចេះនិយាយភាសាបរទេស និងត្រូវបានបដិសេធនូវសិទ្ធិស្របច្បាប់ ។
- មិនថាទៅធ្វើការនៅទីកន្លែងផ្សេង ឬក៏ជាអ្នកដែលរត់ចេញពីផ្ទះឡើយ គឺសុទ្ធតែក្លាយជាកុមារដែលងាយរងគ្រោះធ្ងន់ធ្ងរ ដោយសារការរំលោភបំពាន និងការកេងប្រវ័ញ្ចពីសំណាក់មនុស្សពេញវ័យ ។

## ៦.៣. ដំណោះស្រាយ

### ក). ករណីកុមាររត់ចេញពីផ្ទះ

- ឪពុកម្ដាយ និងញាតិសន្ដានត្រូវជូនដំណឹងទៅអាជ្ញាធរមូលដ្ឋាន
- អាជ្ញាធរមូលដ្ឋាន អាចទាក់ទងទៅមន្ត្រីសង្គមកិច្ច នគរបាល អង្គការមិនមែនរដ្ឋាភិបាលនានាដើម្បីស្វែងរកកុមារ ។





- បើរកកុមារឃើញ ហើយអាចនាំត្រឡប់មកផ្ទះវិញបាន មន្ត្រីសង្គមកិច្ច និងអ្នកពាក់ព័ន្ធត្រូវធ្វើការជាមួយគ្រួសារកុមារ ដើម្បីជួយស្វែងរកដំណោះស្រាយ ចំពោះបញ្ហាដែលធ្វើឱ្យកុមាររត់ចេញពីផ្ទះ ។
- បើកុមាររត់ចេញពីផ្ទះដោយសារការវាយដំ ឬការរំលោភបំពាននានានៅក្នុងផ្ទះ សូមមើលដំណោះស្រាយករណីកុមាររស់នៅក្នុងគ្រួសារដែលមានអំពើហិង្សា ។ ជាការសំខាន់ណាស់ដែលត្រូវធានាថា កុមារនឹងមិនរត់ចេញពីផ្ទះជាថ្មីម្ដងទៀតទេ ។
- ញាតិសន្ដាន និងសមាជិកដទៃទៀតនៅក្នុងសហគមន៍ត្រូវជួយផ្ដល់យោបល់ និងលើកទឹកចិត្តដល់កុមារ ។
- អ្នកទាំងអស់គ្នាត្រូវធ្វើការងារជាមួយឪពុកម្ដាយ ដើម្បីលើកកម្ពស់ការធ្វើសមាហរណកម្មកុមារ ។

### ខ). ករណីកុមារចាកចេញពីសហគមន៍ដើម្បីទៅរកការងារធ្វើ

- ឪពុកម្ដាយត្រូវដឹងពីទីកន្លែងដែលកុមារត្រូវទៅ និងវិធីដែលអាចឱ្យពួកគេទាក់ទងកុមារបានគ្រប់ពេល ។
- បើមានលទ្ធភាព កុមារអាចរស់នៅជាមួយញាតិសន្ដាន ឬមិត្តភក្ដិដែលអាចទុកចិត្តបានរបស់ក្រុមគ្រួសារនៅកន្លែងថ្មី ដែលពួកគេត្រូវទៅនោះ ។ ឪពុកម្ដាយត្រូវទៅពិនិត្យទីកន្លែងដែល

កុមារត្រូវទៅរស់នៅ ដើម្បីធានាថា ទីនោះគឺជាកន្លែងមានសុវត្ថិភាពសម្រាប់កុមាររស់នៅ ។

- ដើម្បីកុំឱ្យកុមារចាកចេញពីសហគមន៍ទៅរកការងារធ្វើ មេភូមិ មេឃុំ ចៅសង្កាត់ មន្ត្រីសង្គមកិច្ច សហគមន៍ និងអ្នកមានសមត្ថកិច្ចដទៃទៀត ត្រូវ :
  - បង្កើតការងារសមស្របសម្រាប់កុមារវ័យជំទង់នៅក្នុងសហគមន៍
  - ជួយបង្កើតជីវភាពដល់ឪពុកម្តាយរបស់កុមារទាំងនោះ
  - . . . ។ល ។

## គ). ករណីកុមារត្រូវគេលួងលោមបោកប្រាស់

- ឪពុក ម្តាយត្រូវទាក់ទងទៅមេភូមិ និងមេឃុំ ចៅសង្កាត់ ដែលជាអ្នកអាចតាមជួយរកទីកន្លែងរបស់កុមារ និងរំដោះកុមារបានដោយមានជំនួយពីនគរបាល និងការិយាល័យសង្គមកិច្ចស្រុក ខណ្ឌ ។
- ឪពុកម្តាយត្រូវតែដឹងជានិច្ចពីទីកន្លែងដែលកុមាររស់នៅ និងមានវិធីអាចទាក់ទងពួកគេបានគ្រប់ពេល ។
- អាជ្ញាធរមូលដ្ឋាន ត្រូវទំនាក់ជាមួយអង្គការមិនមែនរដ្ឋាភិបាល ឬអ្នកផ្តល់សេវាផ្សេងទៀតដើម្បីធ្វើការផ្សព្វផ្សាយ និងផ្តល់នូវ





ការយល់ដឹងអំពីការចាកចេញប្រកបដោយសុវត្ថិភាព ភាពគ្រោះថ្នាក់ និងល្បិចបោកបញ្ឆោតរបស់ជនល្មើស ។

ទោះបីជាកុមារ ត្រូវផ្លាស់ប្តូរទីកន្លែងទៅរស់នៅកន្លែងផ្សេងជាមួយញាតិសន្តាន ឬក្រុមគ្រួសាររបស់មិត្តភក្តិ ឬទៅនៅតាមវត្តអារាម ដែលអាចឱ្យពួកគេបន្តការសិក្សាក៏ដោយ ក៏ឪពុកម្តាយ ឬអ្នកថែទាំបបមត្រូវនាំកុមារទៅទីកន្លែងទាំងនោះ ដើម្បីធានាថា ទីនោះជាទីកន្លែងមានសុវត្ថិភាពសម្រាប់កុមាររស់នៅ និងមានមធ្យោបាយអាចទាក់ទងជាមួយកុមារបានគ្រប់ពេលបើមានការចាំបាច់ ។ កុមារត្រូវតែបានទទួលចំណេះដឹងអំពីវិធីទាក់ទងជាមួយក្រុមគ្រួសារ ឬមេភូមិ ។ កុមារម្នាក់ៗត្រូវតែដឹងពីសិទ្ធិជាមូលដ្ឋានរបស់ខ្លួន និងត្រូវបានប្រាប់ឱ្យដឹងពីភាពគ្រោះថ្នាក់របស់អ្នកជួញដូរកុមារ និងពីល្បិចកលរបស់ឈ្មួញទាំងនោះ ។

# ៧. កុមារពិការ



☞ **កុមារពិការ** គឺជាកុមារមិនអាចមានឯករាជ្យ (គ្មានម្ចាស់ការលើខ្លួនឯង) ឬមិនអាចផ្សារភ្ជាប់ខ្លួនឯងបានពេញលេញ ទៅក្នុងសហគមន៍ ដោយសារតែពិការភាព។

☞ **ពិការភាព** គឺជាកង្វះខាត ឬការគ្មានលទ្ធភាពក្នុងការធ្វើសកម្មភាពដូចមនុស្សធម្មតា ឬក្នុងកម្រិតដែលមនុស្សធម្មតាអាចធ្វើបាន។ ពិការភាព អាចប៉ះពាល់ទៅលើរាងកាយ ខួរក្បាល លទ្ធភាពក្នុងការរៀនសូត្រ ការនិយាយស្ដី ឬអាកប្បកិរិយា ...។ល។ (អង្គការសុខភាពពិភពលោក)។

## ៧.១. អត្តសញ្ញាណនៃពិការភាពរបស់កុមារ

យើងអាចសម្គាល់ពិការភាពរបស់កុមារបានដូចខាងក្រោម :





| ប្រភេទ | ការពន្យល់ | លក្ខណៈពិការភាព |
|---|---|---|
| **ពិបាកក្នុងការមើល** | អ្នកទាំងឡាយណាដែលមានលទ្ធភាពមើលឃើញតិចតួច លទ្ធភាពសម្លឹងមើលចុះខ្សោយ ឬមិនអាចមើលឃើញវត្ថុអ្វីមួយ។ | ឧទាហរណ៍ : ងងឹតភ្នែកម្ខាង ឬទាំងសងខាង ស្វិតឬរលាកសសៃបាតភ្នែក ភ្នែកល្មៀនមើលមិនឃើញ កន្ទុយថ្លែន ត្រាក់កូម ស្រលៀងភ្នែក ភ្នែកមីញ៉ូប ធ្លាក់ត្របកភ្នែក សម្លាកកញ្ចក់ភ្នែក ជំងឺប្រែងចាក់ភ្នែក សម្ពាធទឹកក្នុងភ្នែក ងងឹតតពួជ រោមភ្នែករមូលចូលក្នុងភ្នែក។ |
| **ពិបាកក្នុងការស្ដាប់** | អ្នកទាំងឡាយណាដែលមានលទ្ធភាពស្ដាប់ចុះខ្សោយ (ពីកំណើត របួស ឬមេរោគ) | ឧទាហរណ៍ : មនុស្សថ្លង់ ត្រចៀកអត់រន្ធ ពុំមានក្រដាសត្រចៀក ធ្លាយក្រដាសត្រចៀក ហៀរអំបៅ អំបែក . . .។ |
| **ពិបាកក្នុងការនិយាយ** | អ្នកទាំងឡាយណាដែលពិបាកក្នុងការនិយាយ និយាយមិនច្បាស់ ឬនិយាយមិនរួចទាល់តែសោះ ឬអ្នកដទៃពិបាកស្ដាប់។ | ឧទាហរណ៍ : អ្នកនិយាយជំទ្បាន់ ត្រដិត ឆែបបបូរមាត់ ឆែបក្រអូមមាត់ ក្ញូវ អណ្ដាតធំ និយាយមិនច្បាស់ អ្នកមានបញ្ហាធ្មេញ។ |

| ប្រភេទ | ការពន្យល់ | លក្ខណៈពិការភាព |
|---|---|---|
| **ពិបាកក្នុងការធ្វើចលនា** | អ្នកទាំងឡាយណាដែលមានលទ្ធភាពធ្វើចលនា (ដោយរាងកាយ) បន្លាស់ទីដោយលំបាក ឬកម្រើកផ្នែកណាមួយនៃរាងកាយរបស់ខ្លួនដោយលំបាក ឬមិនអាចកម្រើកបានទាល់តែសោះ។ | ឧទាហរណ៍ : ពិការដៃ ពិការជើង ស្វិតដៃជើង ស្វិតសាច់ដុំ គាំងសរសៃបាក់ឆ្អឹង សាច់ដុំតឹងខ្លាំង ខូចគ្រឿងបញ្ជាចលនា ខួរក្បាល ជើងខ្វេ ជើងកែក ទន់ត្រឹមកដៃ ជើងទន់ ខូចទ្រង់ទ្រាយពីកំណើត ស្លាប់មួយចំហៀង ស្លាប់អវៈយវៈ ស្លាប់សរសៃ ឆ្អឹងខ្នងវៀច រលាកសន្លាក់ហើម រលាកឆ្អឹងសន្លាក់ របេងឆ្អឹងគមខ្នង (កោងទៅមុខ កោងទៅចំហៀង និងកោងទៅក្រោយ) ខូចស្នាម្ខាង ភ្លាត់ត្រគាក របួសខួរឆ្អឹងខ្នង គ្រិច រលាកភ្លើង ឬទឹកអាស៊ីដ ជំងឺឆ្អឹងទន់ ...។ |
| **ពិបាកខាងកាយវិញ្ញាណ** | អ្នកទាំងឡាយណាដែលបាត់បង់ការដឹង ដោយកាយវិញ្ញាណ ឬអត់ដឹងនៅពេលកាន់ ឬស្ទាបវត្ថុអ្វីមួយ។ | ឧទាហរណ៍ : អ្នកពិការដោយសារឃ្លង់ (កម្រិតធ្ងន់) អ្នកស្ពឹកដៃជើង កង្វះជីវជាតិ (ហើម) ... ។ |





| ប្រភេទ | ការពន្យល់ | លក្ខណៈពិការភាព |
|---|---|---|
| **ពិបាកខាងផ្លូវចិត្ត** | អ្នកទាំងឡាយណាដែលមានវិបត្តិផ្លូវចិត្ត មានអាកប្បកិរិយាខុសពីមនុស្សធម្មតា។ | ឧទាហរណ៍ : អ្នកដែលដើរគ្មានសម្លៀកបំពាក់ អ្នកដែលនិយាយសើច ច្រៀងរាំលេងតែម្នាក់ឯងខុសពីប្រក្រតី ស្ងឹងស្ងាធ ជេរគេជេរឯង វាយ ឬប្រព្រឹត្តិអំពើហិង្សាដោយមិនដឹងខ្លួន មិនដឹងគ្រោះថ្នាក់ វិកលចរិត ឆ្កួតសតិអារម្មណ៍ តានតឹងផ្លូវចិត្ត ធ្លាក់ទឹកចិត្ត ថប់អារម្មណ៍។ |
| **ពិបាកក្នុងការរៀនសូត្រ** | អ្នកទាំងឡាយណាដែលមានលទ្ធភាពចងចាំខ្សោយ ភ្លេចច្រើន ឬមិនអាចធ្វើអ្វីមួយដូចអ្នកដទៃទៀតដែលមានអាយុដំណាលគ្នាធ្វើបាន។ | ឧទាហរណ៍ : អ្នកដែលមានបញ្ញាល្ងង់លាស់យឺត ដោនស៊ីនដ្រូម អ្នករៀនខ្សោយ ការចងចាំនៅមានកម្រិត ខូចប្រព័ន្ធបញ្ញាក្នុងខួរក្បាល ក្មេងដែលមានចរិតទុយមុយ ... ។ |
| **អ្នកដែលឧស្សាហ៍ប្រកាច់** | អ្នកទាំងឡាយណាដែលមានការប្រកាច់ជាញឹកញាប់ ព្រមទាំងបែកពពុះមាត់ ដោយមូលហេតុអ្វីមួយ។ | ឧទាហរណ៍ : អ្នកដែលមានជំងឺឆ្កួតជ្រូក ក្តៅប្រកាច់ ប្រកាច់ដោយសារលើសជាតិស្ករ ឬខ្វះជាតិស្ករ នៅក្នុងឈាម ... ។ |

| ប្រភេទ | ការពន្យល់ | លក្ខណៈពិការភាព |
|---|---|---|
| ពិការផ្សេងៗ | អ្នកទាំងឡាយណាដែលមានការលំបាកក្នុងការបំពេញតួនាទីផ្នែករាងកាយ ឬតួនាទីក្នុងសង្គម ឬពិការដែលមិនអាចចាត់ចូលទៅក្នុងប្រភេទពិការណាមួយខាងលើ។ | ឧទាហរណ៍ : អ្នកដែលមានមុខមាត់ខូច ទ្រង់ទ្រាយអាក្រក់ អ្នកដែលមានជំងឺរុំារ៉ៃ មនុស្សតឿ ក្រិនផ្លែលើស្បែក (កម្រិតខ្លាំង) អ្នកមានមេរោគអេដស៍ ក្មេងមានក្បាលធំ ... ។ |

## ៧.២. ភាពរងគ្រោះរបស់កុមារពិការ

កុមារពិការតែងតែទទួលរងគ្រោះមួយចំនួនដូចជា :

- ពួកគេមិនអាចដើរ រត់លេងកំសាន្ត ឬថែទាំរាងកាយរបស់ខ្លួនបានដូចកុមារដទៃទៀតដែលមិនពិការ។
- ពួកគេមិនអាចទំនាក់ទំនងជាមួយមនុស្សដទៃបានដោយស្រួល
- ពិបាកក្នុងការទៅសាលារៀន ឬមិនអាចរៀនសូត្របាន
- អាកប្បកិរិយារបស់ពួកគេស្តែងឡើងខុសប្លែកពីគេ និងមិនអាចឱ្យមនុស្សដទៃទៀតយល់បាន។
- ជាញឹកញាប់ណាស់ កុមារពិការតែងតែត្រូវគេរើសអើង ហើយឪពុកម្តាយរបស់កុមារទាំងនោះអាចនឹងមានគំនិតថា វាគឺជាការអាម៉ាស់ដោយសារកូនពិការ ហើយព្យាយាមលាក់បាំងកូនរបស់ខ្លួនពីមនុស្សទាំងឡាយនៅក្នុងសហគមន៍ ...។ល។





## ៧.៣. ការឆ្លើយតបចំពោះកុមារពិការ

នេះគឺជាចំណុចសំខាន់ណាស់ដែលត្រូវចងចាំថា កុមារពិការក៏ជាកុមារដែរ។ ពួកគេត្រូវការសេចក្តីស្រឡាញ់ ការយកចិត្តទុកដាក់ ការថែទាំ ការយល់ចិត្ត ជាងកុមារធម្មតា។ ក្រុមគ្រួសាររបស់កុមារទាំងនេះមិនត្រូវមានការអាម៉ាស់ដោយសារកូនរបស់ខ្លួនពិការឡើយ ហើយមនុស្សទាំងឡាយ នៅក្នុងសហគមន៍ត្រូវតែយល់ឱ្យច្បាស់អំពីបញ្ហានេះ ហើយមិនត្រូវរើសអើងចំពោះកុមារពិការឡើយ។ មានអង្គការមិនមែនរដ្ឋាភិបាលជាច្រើនដែលអាចជួយដល់កុមារពិការ។ ជាការសំខាន់មួយដែលកុមារពិការត្រូវទទួលបានសេវាសុខភាពយ៉ាងឆាប់រហ័សក្នុងជីវិតរបស់គេ ដោយហេតុថា ពិការភាពមួយចំនួនអាចព្យាបាលឱ្យជាសះស្បើយឡើងវិញ ដោយការវះកាត់ ការព្យាបាល ឬដោយវិធីផ្សេងៗទៀត។

# ៨. កុមារទំនាស់នឹងច្បាប់

កុមារទំនាស់នឹងច្បាប់ គឺកុមារអាយុក្រោម១៨ឆ្នាំ ដែលត្រូវបានសង្ស័យ ចោទប្រកាន់ ឬទទួលស្គាល់ថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ កុមារបែបនេះត្រូវទទួលបាន នូវការប្រព្រឹត្តពិសេស មិនដូចនឹងជនល្មើសដែលជាមនុស្សពេញវ័យឡើយ។

## ៨.១. ការប្រព្រឹត្តរបស់នគរបាលទៅលើកុមារ



- នគរបាលគប្បីប្រព្រឹត្តទៅលើកុមារដែលជាជនល្មើសដោយសេចក្តីថ្លៃថ្នូរ។
- កុមារដែលប្រព្រឹត្តបទល្មើសមិនត្រូវទទួលរងការវាយដំ មិនត្រូវគេសម្រាតសម្លៀកបំពាក់ ឬជេរប្រមាថឡើយ។
- នគរបាលអាចធ្វើការទំនាក់ទំនងជាមួយកុមារដែលជាជនល្មើសតាមរយៈការជជែកពិភាក្សាគ្នា ពោលគឺមិនមែនតាមរយៈការប្រើអំពើហិង្សានោះទេ។





## ៨.២. ការជំនុំជម្រះរឿងក្តី និងការឃុំខ្លួន

### ក). មុនពេលជំនុំជម្រះរឿងក្តី



- ត្រូវដាក់កុមារនៅក្រៅពន្ធនាគារ ឬកន្លែងដែលមានសុវត្ថិភាពទៅតាមលទ្ធភាពដែលអាចធ្វើបាន។
- កុមារដែលមានអាយុក្រោម១៣ឆ្នាំ មិនត្រូវស្ថិតក្នុងការឃុំឃាំងបណ្តោះអាសន្នឡើយ (មាត្រាទី១៤ច្បាប់ព្រហ្មទណ្ឌអន្តរកាល)។
- ដាក់កុមារនៅក្នុងពន្ធនាគារ គឺជាជម្រើសចុងក្រោយបំផុត និងក្នុងរយៈពេលមួយជាអប្បបរមាតាមដែលអាចធ្វើបាន។
- កុមារត្រូវទទួលខុសត្រូវចំពោះអំពើខុសឆ្គងរបស់ខ្លួន តាមមធ្យោបាយមួយដែលគោរពដល់សេចក្តីថ្លៃថ្នូរ និងការលើកទឹកចិត្តឱ្យកុមារកែប្រែអាកប្បកិរិយា (ឧទាហរណ៍ : សុំទោសជនរងគ្រោះ ទទួលការអប់រំ និងចូលរួមក្នុងសកម្មភាពសាធារណៈណាមួយ)
- អនុញ្ញាតឱ្យកុមារបានស្នាក់នៅជាមួយឪពុកម្តាយ និងទៅសាលារៀន

## ខ). ក្នុងអំឡុងពេលជំនុំជម្រះរឿងក្តី



- ក្នុងអំឡុងពេលនៃការរងចាំការជំនុំជម្រះរឿងក្តី ជាការចាំបាច់បើអាចធ្វើបាន កុមារត្រូវរស់នៅជាមួយក្រុមគ្រួសារ ឬសហគមន៍ គឺមិនមែននៅក្នុងពន្ធនាគារឡើយ ។
- កុមារដែលជាប់ចោទមានសិទ្ធិទទួលបាន ជំនួយពីមេធាវី និងមានវត្តមានឪពុក ម្តាយ ឬអាណាព្យាបាលរបស់គេនៅគ្រប់ដំណាក់កាលនៃដំណើរការរឿងក្តី ។
- អ្នកធ្វើការខាងសង្គមកិច្ចត្រូវចូលរួមផ្តល់ព័ត៌មានអំពីកុមារ និងផ្តល់ការគាំទ្រផ្នែកសតិអារម្មណ៍ ។





## គ). ល័ក្ខខ័ណ្ឌនៃការឃុំខ្លួនកុមារដែលជាជនល្មើស



- មានតែនៅក្នុងករណីដែលធ្ងន់ធ្ងរប៉ុណ្ណោះ ដែលកុមារអាចនឹងត្រូវឃុំខ្លួន ដើម្បីសុវត្ថិភាពជនរងគ្រោះ ឬសហគមន៍
- នៅក្នុងពន្ធនាគារ ត្រូវដាក់កុមារឱ្យនៅដាច់ដោយឡែកពីជនល្មើសដែលជាមនុស្សពេញវ័យ
- ត្រូវមានកន្លែងសមល្មម និងមានខ្យល់អាកាសល្អ មានអាហារូបត្ថម្ភគ្រប់គ្រាន់ មានទឹកស្អាត និងសម្លៀកបំពាក់ដែលមានអនាម័យ
- ទទួលបានការហាត់ប្រាណ និងការចេញទៅលំហែកាយក្រៅបន្ទប់ យ៉ាងតិច១ម៉ោងក្នុង១ថ្ងៃ ។
- មានសិទ្ធិជួបជាមួយញាតិសន្តាន ដែលមកសួរសុខទុក្ខយ៉ាងតិច

១ម៉ោងក្នុងមួយសប្តាហ៍

- មានសិទ្ធិបន្តការសិក្សា ឬចូលរួមវគ្គបណ្តុះបណ្តាលនានា
- មានសិទ្ធិទទួលបានការព្យាបាល

## ៨.៣. ចំណុចគួរចងចាំ

☞ កុមារគ្រប់រូបអាយុក្រោម១៨ឆ្នាំ ដែលប្រព្រឹត្តអំពើទំនាស់នឹងច្បាប់ ត្រូវទទួលនូវការប្រព្រឹត្តជាពិសេសមកលើខ្លួន ពោលគឺមិនត្រូវបានគេប្រព្រឹត្តមកលើខ្លួន ដូចជនល្មើសដែលជាមនុស្សពេញវ័យឡើយ ទោះជាបទល្មើសនោះធ្ងន់ធ្ងរបែបណាក៏ដោយ ។

☞ ចូរចងចាំថា កុមារប្រព្រឹត្តអំពើទំនាស់នឹងច្បាប់ អាចបណ្តាលមកពីមូលហេតុច្រើនយ៉ាងដូចជា ភាពក្រីក្រ ការមិនអើពើយកចិត្តទុកដាក់ ឬការរំលោភបំពានពីសំណាក់ឪពុកម្តាយ អាណាព្យាបាល ឬជនណាមួយ កង្វះការអប់រំណែនាំ កង្វះសកម្មភាពដែលមានអត្ថប្រយោជន៍នៅក្នុងសង្គម រងការគាបសង្កត់ពីមិត្តភក្តិ (ឧទាហរណ៍ : ក្រុមបងធំ) ការបង្ខិតបង្ខំពីមនុស្សពេញវ័យ ឬការសេពសារធាតុញៀនជាដើម ។

☞ លើកស្ទួយការគោរពសេចក្តីថ្លៃថ្នូរពីកំណើត ចំពោះកុមារទំនាស់នឹងច្បាប់ ។ ការពារកុមារពីការសងសឹក ឬអំពើហិង្សានៅក្នុងសហគមន៍ ។ កុមារអាចរៀនសូត្រពីជីវិតបានល្អ តាមរយៈការផ្តល់ហេតុផល មិនមែនតាមរយៈអំពើហិង្សានោះទេ ។



៨. កុមារទំនាស់នឹងច្បាប់

☞ ចូរចងចាំថា ការបង្ករបួសស្នាមទៅលើជនជាប់សង្ស័យ ទោះជាអ្នកនោះជាកុមារ ឬជាមនុស្សពេញវ័យក្តី គឺជាបទល្មើសព្រហ្មទណ្ឌ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ។

☞ លើកទឹកចិត្តដល់គ្រួសារ ក្នុងការណែនាំកូនឱ្យមានអាកប្បកិរិយាល្អ ។ ផ្តល់ឱកាសឱ្យកុមារទទួលខុសត្រូវ ចំពោះអំពើខុសឆ្គងរបស់ខ្លួន តាមរយៈសកម្មភាព ដែលជួយស្តារការខូចខាតរបស់ជនរងគ្រោះ (ឧទាហរណ៍ : ការសុំទោស ការសង ...) និងលើកទឹកចិត្តឱ្យកុមារកែប្រែអាកប្បកិរិយា ។

☞ករណីកុមារត្រូវបាននគរបាលចាប់ខ្លួន ត្រូវជូនដំណឹងភ្លាមទៅឪពុកម្តាយរបស់កុមារ ឬសាច់ញាតិជិតបំផុត ឬអាណាព្យាបាលអំពីឧប្បត្តិហេតុ និងទីកន្លែងដែលកុមារកំពុងស្ថិតនៅ ។ ឪពុកម្តាយ ឬអាណាព្យាបាលរបស់កុមារ មានសិទ្ធិចូលរួមនៅក្នុងដំណើរការនៃការស៊ើបអង្កេត និងការជំនុំជម្រះរឿងក្តី ។

☞ បញ្ជូនករណីទៅរកសេវាសង្គមកិច្ច (មន្ត្រីសង្គមកិច្ចថ្នាក់ស្រុក ខណ្ឌ និងថ្នាក់ខេត្ត ក្រុង) ។ កុមារមានសិទ្ធិទទួលនូវជំនួយឧបត្ថម្ភពីអ្នកធ្វើការងារសង្គមកិច្ចនៅក្នុងដំណាក់កាលស៊ើបអង្កេត និងជំនុំជម្រះ ។ ករណីចាំបាច់ត្រូវបញ្ជូនកុមារទៅអង្គការ ដែលអាចផ្តល់ជំនួយជាសេវានានា (ឧទាហរណ៍ : ការថែទាំសុខភាព ការគាំទ្រផ្នែកអារម្មណ៍ និងការប្រឹក្សាយោបល់ជាដើម) ។

- ឃ្លាំមើលពីរយៈពេលនៃការឃាត់ឬឃុំខ្លួនកុមារ ។ ជូនដំណឹងទៅអ្នកធ្វើការងារសង្គមកិច្ច មេធាវី ឬអាជ្ញាធរ ឬអង្គការពាក់ព័ន្ធក្នុងករណីមានការឃាត់ ឬឃុំខ្លួនកុមារលើសរយៈពេលកំណត់ដោយច្បាប់ ។
- បញ្ជូនកុមារ និងឪពុកម្តាយ ឬអាណាព្យាបាលរបស់កុមារទៅរកមេធាវី ឬក្រុមផ្តល់ជំនួយផ្នែកច្បាប់នៅក្នុងសហគមន៍របស់អ្នក ។ កុមារជាជនជាប់ចោទ មានសិទ្ធិទទួលជំនួយពីមេធាវីនៅក្នុងដំណាក់កាលនៃការស៊ើបអង្កេត និងជំនុំជម្រះ ។
- ជួយកុមារទំនាស់នឹងច្បាប់ ឱ្យបានចូលរៀនក្នុងប្រព័ន្ធសិក្សាផ្លូវការ ឬបើមិនអាចធ្វើបានទេ ឱ្យបានចូលរៀន ឬការបណ្តុះបណ្តាលវិជ្ជាជីវៈក្រៅប្រព័ន្ធ ។ លើកស្ទួយការប្រឹក្សាយោបល់ តម្លៃនៃការអប់រំ និងការបណ្តុះបណ្តាលលើផ្នែកបំណិនជីវិត ដើម្បីបង្ការកុំឱ្យកុមារប្រព្រឹត្តបទល្មើសសាជាថ្មី ។
- លើកទឹកចិត្តឱ្យស្រុះស្រួលគ្នារវាងកុមារដែលបានប្រព្រឹត្តល្មើស និងជនរងគ្រោះ ក៏ដូចជាក្រុមគ្រួសារនៃអ្នកទាំងនោះផងដែរ ដើម្បីធានាឱ្យមានការធ្វើសមាហរណកម្មកុមារទៅក្នុងសង្គម និងភាពសុខសាន្តនៅក្នុងសហគមន៍ ។